អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១០

# សេចក្តីប្រកាសព័ត៌មាន

## សាធារណជនចំនួន៣២,៦៣៣នាក់ បានមកធ្វើទស្សនកិច្ចសិក្សានៅសាលាក្តីខ្មែរក្រហមក្នុងឆ្នាំ ២០១០

សាធារណជនចំនួន៣២,៦៣៣នាក់ បានមកធ្វើទស្សកិច្ចសិក្សានៅសាលាក្តីខ្មែរក្រហម ក្នុងកំឡុងពេលសវនាការសាធារណៈ យៈពេល៤ថ្ងៃ និងដំណើរទស្សនកិច្ចសិក្សាចំនួន៨៥ក្រុមក្នុងឆ្នាំ២០១០នេះ។

ដំណើរទស្សនៈកិច្ចសិក្សានេះ គឺជាកម្មវិធីដែលប្រព្រឹត្តិទៅពេញមួយថ្ងៃ សំរាប់សិស្សនិស្សិត លោកគ្រូអ្នកគ្រូ និងប្រជាពលរដ្ឋមកពីគ្រប់ច្រកល្ហកក្នុងប្រទេសកម្ពុជា មានឱកាសមកទស្សនាផ្ទាល់នៅតុលាការខ្មែរក្រហម ព្រមទាំងទៅទស្សនាសារៈមន្ទីរប្រល័យពូជសាសន៍ទួលស្លែង។

ដំណើរទស្សនកិច្ចនេះប្រព្រឹត្តិទៅចំនួនពីរលើកក្នុងមួយសប្តាហ៍ ហើយអនុញ្ញាតឲ្យប្រជាពលរដ្ឋចំនួនពី ៣០០ ទៅ ៤៥០នាក់ មានឱកាសបានចូលរួម។ ដំណើរទស្សនកិច្ចនេះ មានគោលបំណងជួយផ្តល់ចំណេះដឹងជូនប្រជាជនទូទៅ ដើម្បីឲ្យបានយល់ដឹងបន្ថែមទៀត អំពីនីតិវិធីជំនុំជម្រះក្តី របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

គិតរហូតមកដល់ពេលនេះ មានប្រជាពលរដ្ឋមកពី២៤ខេត្តក្រុងហើយ បានមកចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សានេះ។ ដំណើរទស្សនកិច្ចនេះ នឹងប្រព្រឹត្តិទៅបន្តទៀតក្នុងឆ្នាំ ២០១១ រហូតដល់មានសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង០០២។

| **សវនាការសាធារណៈ និងដំណើរទស្សនកិច្ចសិក្សា** | |
|---|---|
| សេចក្តីបង្ហាញ | ២០១០ |
| *I. ប្រជាពលរដ្ឋទូទៅតាមបណ្តាខេត្តក្រុង* | |
| 1. ស្វាយ រៀង | 1,685 |
| 2. កំពង់ចាម | 3,190 |
| 3. សៀម រាប | 2,345 |
| 4. កំពង់ ធំ | 2,715 |
| 5. ព្រះសីហានុ | 360 |
| 6. ពោធិសាត់ | 110 |
| 7. កំពង់ស្ពឺ | 1,570 |
| 8. ព្រៃវែង | 690 |
| 9. កោះ កុង | 270 |
| 10. តាកែវ | 1,790 |

| | |
|---|---|
| 11. កំពត | 2,245 |
| 12. បន្ទាយមានជ័យ | 1,120 |
| 13. ក្រចេះ | 1,170 |
| 14. កណ្តាល | 2,446 |
| 15. ព្រះវិហារ | 1,260 |
| 16. បាត់ដំបង | 1,040 |
| 17. ឧត្តមានជ័យ | 670 |
| 18. ស្ទឹង ត្រែង | 1,716 |
| 19. កែប | 1,090 |
| 20. រតនគីរី | 320 |
| 21. ភ្នំពេញ | 1,963 |
| 22. កំពង់ឆ្នាំង | 760 |
| 23. ប៉ៃលិន | 375 |
| 24. មណ្ឌលគីរី | 390 |
| ***II . សាកលវិទ្យាល័យ និងស្ថាប័នផ្សេងៗ*** | 201 |
| ***III . អង្គការក្រៅរដ្ឋាភិបាល*** | 286 |
| ***IV . ដើមបណ្តឹងរដ្ឋប្បវេណី*** | 229 |
| ***V. ភ្ញៀវអន្តរជាតិ*** | 207 |
| ***VI. ភ្ញៀវ VIPs និងមន្ត្រីរដ្ឋាភិបាល*** | 60 |
| ***VII. តំណាងសារព័ត៌មាន*** | |
| ជាតិ | 230 |
| អន្តរជាតិ | 130 |
| **សរុប (I+II+III+IV+V+VI+VII)** | ***32,633*** |

ចំនួនអ្នកចូលរួមក្នុងឆ្នាំ២០១០ ដ៏ច្រើនកុះករនេះ បង្ហាញឲ្យឃើញយ៉ាងច្បាស់ថា សាធារណជនទូទៅនៅតែបន្តការចាប់អារម្មណ៍ក្នុងការស្វែងយល់ ពីនីតិវិធីជំនុំជម្រះក្តីរបស់អ.វ.ត.កបន្តទៅទៀត។ ចាប់តាំងពីថ្ងៃចាប់ផ្តើមសវនាការសាធារណៈកាត់ទោសសំណុំរឿង ០០១ កាំង ហ្គេកអ៊ាវ ហៅ ឌុច នាថ្ងៃទី៣០ ខែមិនា ឆ្នាំ២០០៩មក មានសាធារណជនរហូតទៅដល់ ៦៧,០០០នាក់បានមកចូលរួមទស្សនាសវនាការ និងទស្សនកិច្ចសិក្សាដោយផ្ទាល់នៅ អ.វ.ត.ក។